ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ២៥៧/០៥-០៧-២០១២

សាលដីកា

លេខ ២៨ក្រVI "វ" /១៦-១១-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣-១០-២០១២ ។

**<u>ក្រុមប្រឹក្សាជំនុំជំរះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>ក្រឡាបញ្ជី</u>**

លោក [redacted]

**ដើមចោទឈ្មោះ អ៊ុន ចាន់ថា** ភេទប្រុស អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរពាណិជ្ជករ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ១៩AE0 ផ្លូវលេខ១១១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

មានលោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិ

**ចុងចម្លើយឈ្មោះ [redacted] ហ៊ីម** ភេទប្រុស អាយុ៥៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ២០២អា ផ្លូវលេខ៣១០ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មានលោក [redacted] មេធាវីតំណាងដោយអាណត្តិ

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖**

ដើមចោទទាមទារទី១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ហ៊ីម ប្រគល់ប្រាក់ថ្លៃលក់រថយន្តម៉ាកCAMARY XLE 2003 ពណ៌ស្ករ តម្លៃ១៧.៣០០$us ឲ្យមកដើមចោទ ទី២-បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] ចាន់ថា និងចុងចម្លើយឈ្មោះ [redacted] ហ៊ីម ទូទាត់បែងចែកភាគហ៊ុនលក់រថយន្តផ្តាច់ពីគ្នា ទី៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ហ៊ីម សងជម្ងឺចិត្តការខាតបង់ពេលវេលាចំនួន១០.០០០$us ឲ្យមកដើមចោទ ទី៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។



Scanned with CamScanner

បណ្តឹងតបរបស់ចុងចម្លើយឈ្មោះ [redacted] ហ៊ឹម ទាមទារទី១-បង្គាប់ឲ្យឈ្មោះ [redacted] ចាន់ថា សងប្រាក់ចំនួន១៨.០០០$us ទី២-បង្គាប់ឲ្យឈ្មោះ [redacted] ចាន់ថា ប្រគល់មកឲ្យខ្លួនវិញនូវរថយន្ត០១គ្រឿងម៉ាក TOYOTA HIGHLANDER ឆ្នាំផលិត២០០២ ពណ៌ខ្មៅ មានលេខតួ JTHF21A720076057 លេខម៉ាស៊ីនIMD1355363 ក្រដាសពន្ធ ទី៣-សុំអនុវត្តជាបណ្តោះអាសន្ន ទី៤-សុំឲ្យឈ្មោះ [redacted] ចាន់ថា ត្រូវបានរ៉ាប់រងលើប្រាក់ប្រដាប់ក្តី។

**អង្គហេតុ និងចំណុចវិវាទ ៖**

ដើមចោទឈ្មោះ [redacted] ចាន់ថាអះអាងថាខ្លួន និងចុងចម្លើយឈ្មោះ [redacted] ហ៊ឹម បានរកស៊ីចូលហ៊ុនគ្នាទិញលក់រថយន្ត ដោយបានទិញរថយន្តចំនួន០៤គ្រឿង សម្រាប់លក់សរុបជាទឹកប្រាក់ចំនួន$១០៥.៣០០(ដប់ម៉ឺនប្រាំពាន់បីរយដុល្លាអាមេរិច)គឺ៖

១.រថយន្តម៉ាក CAMARY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ$១៦.៥០០(មួយម៉ឺនប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិច) ។

២.រថយន្តម៉ាក CAMARY XLE 2003 ពណ៌ស្គរ តម្លៃ$១៧.៣០០(មួយម៉ឺនប្រាំពីរពាន់បីរយដុល្លាអាមេរិច)

៣.រថយន្តម៉ាក CAMARY HYBRID 2010 ពណ៌ខ្មៅតម្លៃ$៣៦.៥០០(បីម៉ឺនប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិច)

៤.រថយន្តម៉ាក CAMARY XLE 2010 ពណ៌ស្លែ តម្លៃ$៣៥.០០០(បីម៉ឺនប្រាំពាន់ដុល្លាអាមេរិច)

ក្នុងនោះដើមចោទបានចេញប្រាក់ដើមចំនួន$៧២.៣០០ (ប្រាំពីរម៉ឺនពីរពាន់បីរយដុល្លាអាមេរិច)ហើយចុងចម្លើយចេញប្រាក់ដើមចំនួន$៣៣.០០០(បីម៉ឺនបីពាន់ដុល្លាអាមេរិច) ។ពេលលក់រថយន្តម៉ាក CAMARY HYBRID 2010 ពណ៌ខ្មៅ តម្លៃ$៣៦.៥០០ ចុងចម្លើយបានដកយកប្រាក់ដើមដែលខ្លួនបានចេញចំនួន$៣៣.០០០គ្រប់ចំនួនរួចរាល់ ហើយខ្លួនក៏បានទទួលស្គាល់ដែរ ។ ដូច្នេះរថយន្ត៣គ្រឿងទៀតដែលនៅសល់ជារបស់ដើមចោទទាំងអស់ ។ ក្រោយមក ពេលលក់រថយន្តម៉ាក CAMARY XLE 2003 ពណ៌ស្គរ តម្លៃ$១៧.៣០០(មួយម៉ឺនប្រាំពីរពាន់បីរយដុល្លាអាមេរិច)បានចុងចម្លើយមិនព្រមប្រគល់ប្រាក់ថ្លៃលក់រថយន្តនេះមកអោយដើមចោទទេ ដែលការពិតប្រាក់ដើមថ្លៃរថយន្តនេះជាប្រាក់របស់ខ្ញុំ។

បណ្តឹងតបរបស់ចុងចម្លើយឈ្មោះ [redacted] ហ៊ឹម អះអាងថា:ខ្លួននិងឈ្មោះ [redacted] ចាន់ថា មានទំនាក់ទំនងហ៊ុនគ្នារកស៊ីទិញ លក់រថយន្ត ការរកស៊ីពុំដែលមានបញ្ហាជាមួយនឹងគ្នាទេ ដោយឡែកកាលពីថ្ងៃទី២៣-១១-២០១០យើងទាំងពីរនាក់បានទិញរថយន្តចំនួន០៤គ្រឿង ដោយចែកគ្នាចេញថ្លៃរថយន្តម្នាក់០២គ្រឿង (ដើមបណ្តឹងចេញថ្លៃCAMRYXLE 2002 ពណ៌ប្រាក់១៦.៥០០$us CAMRY HIBRID 2010 ៣៦.៥០០$us ចុងចម្លើយចេញថ្លៃ CAMRY 2010 ពណ៌ស្លែ ៣៥.០០០$us CAMRY XLE 2003 ពណ៌ស្គរ ១៧.៣០០$us)។ រថយន្តដែលបានលក់៣គ្រឿងដំបូងគឺបានទូទាត់ប្រាក់ដើម និងប្រាក់ចំណេញជាមួយគ្នា អស់

ហើយ ចំពោះរថយន្តដែលលក់ចុងក្រោយគេ CAMRY XLE 2002 ពណ៌ប្រាក់១៦.៥០០ $us ដែលឈ្មោះ[redacted] ចាន់ថា បានលក់ចេញរួចរាល់ហើយ ប៉ុន្តែ[redacted] ចាន់ថា ពុំទាន់បានទូទាត់ប្រាក់ដើមនិងប្រាក់ចំណេញមកឲ្យខ្លួននៅឡើយទេ ដោយគាត់អះអាងថា រថយន្តនោះគាត់ជាអ្នកចេញប្រាក់សងគេ ប៉ុន្តែជាតុពិតឡានមួយគ្រឿងនេះគឺខ្លួនជាអ្នកចេញសងព្រោះភាគីហ៊ុនទាំងពីរបានព្រមព្រៀងគ្នាទូទាត់កាត់កងលុយគ្នា ដែលបានគិតបញ្ជីជាមួយគ្នានៅថ្ងៃទី០៧-១២-២០១០ដោយគាត់កាត់កងឡានCAMRY XLE 2002 ពណ៌ប្រាក់ដាក់ជាកម្មសិទ្ធិរបស់ខ្ញុំជាចេញប្រាក់សង ហើយមានបញ្ជាក់ឈ្មោះខ្ញុំជាអ្នកចេញសងថ្លៃឡាននេះក្នុងបញ្ជីជាលាយលក្ខ័អក្សរទាំងសងខាង ហើយថ្លៃជួសជុលឡាននេះក៏ខ្ញុំជាអ្នកចេញថ្លៃជួសជុលទាំងស្រុងដែរ។អង្គហេតុមួយទៀត ដែលទាក់ទងនឹងរថយន្តម៉ាកTOYOTA HIGHLANDER ឆ្នាំផលិត២០០២ ពណ៌ខ្មៅ មានលេខតួJTHF21A 720076057 លេខម៉ាស៊ីនIMD1355363 គ្រដាសពន្ធ ជារថយន្តដែលខ្ញុំជាអ្នកចេញមុខទិញហើយចេញសោហ៊ុយជួសជុលដោយខ្លួនឯង ប៉ុន្តែឈ្មោះ[redacted] ចាន់ថា បែរជាយករថយន្តនេះទៅទុកក្នុងឃ្លាំងឡានទុកជាកម្មសិទ្ធិរបស់គាត់ទៅវិញ។

**<u>ការអះអាងរបស់ភាគីដើមចោទ៖</u>**

លោកស្រី[redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ[redacted] ចាន់ថាថ្លែងហេតុថាៈដោយសាររឿងនេះ ខ្ញុំតំណាងដោយអាណត្តិឲ្យកូនក្តីខ្ញុំតាំងពីសាលាដំបូងមក រឿងខ្លះមានក្នុងពាក្យបណ្តឹងប៉ុន្តែដោយសារក្នុងសាលក្រមអត់មាន ដោយសារនៅពេលនីតិវិធីត្រៀមភាគីទាំងពីរបានព្រមព្រៀងគ្នាហើយ ចំណុចដែលអត់វិវាទចៅក្រមមិនលើកយកមកពិចារណាទេ ហើយគូភាគីទទួលស្គាល់ទាំងសងខាងជាក់ស្តែងរថយន្ត Highlander ដោយគាត់ ទទួលស្គាល់ថាលុយចូលគ្នាស្មើហើយ ដូច្នេះនៅក្នុងសាលក្រមអត់មានរថយន្តហ្នឹងមកចូលទេ ព្រោះគាត់ព្រមព្រៀងទូទាត់ហើយ។ ដោយសារនៅក្នុងឯកសារដែលភាគីចុងចម្លើយលើកឡើងនេះ គាត់សំអាងលើអក្សរដែលកូនក្តីខ្ញុំសរសេរដាក់ថាហ៊ីម ចេញ។ចំណុចវិវាទក្នុងរឿងនេះមានឡានCAMRY ថ្លៃ១៦.៥០០ដុល្លា តែប៉ុណ្ណោះ ចំណុចផ្សេងទៀតមានការទទួលស្គាល់ ព្រមព្រៀងរៀងៗខ្លួន។ហើយនៅក្នុងនីតិវិធីត្រៀម ទាំងពីរលើកបានព្រមព្រៀងហើយ តែមិនដឹងហេតុអីបានជាពេលនេះលោកមេធាវីលើកឡើងនៅសវនាការសាលាឧទ្ធរណ៍។ ក្នុងសៀវភៅកំណត់ហេតុរបស់កូនក្តីខ្ញុំសៀវភៅសរសេរដៃទេ ហើយការសរសេរនេះដូចខ្ញុំធ្លាប់លើកឡើងក្នុងសាលក្រមអីចឹងគាត់សរសេរពេលដែលគាត់ទិញឡានសរុបមកជាង១០ម៉ឺនដុល្លា ហើយគាត់សរសេរព្រៀងមុនថាតឡូវក្នុង៤គ្រឿងហ្នឹងភាគីកូនក្តីខ្ញុំចេញអី ភាគីខាងលោកហ៊ីម ចេញអី។ នេះគ្រាន់ជាការគ្រោងមុនទេលុយមិនទាន់ចេញទេ។ពេលទិញជាមួយគ្នាតែអត់ទាន់ ឲ្យលុយគេទេ ហើយហ៊ីមថាឡានថ្លៃ១៦.៥០០ដុល្លា គាត់ចេញ អីចឹងហើយកូនក្តីខ្ញុំសរសេរក្នុងសៀវភៅកំណត់ដៃធម្មតា។ហើយឡាន៣គ្រឿងទៀតកូនក្តីខ្ញុំចេញ ប៉ុន្តែសរុបទាំងអស់

១០៥.៣០០ដុល្លា តែពេលចេញលុយគឺចេញផ្សេងពីនេះ ហើយវាស៊ីសង្វាក់គ្នាទៅ នឹង ការបំភ្លឺ របស់លោក [redacted] ស៊ីហ្វុង ដែលបានទទួលលុយពីកូនក្តីរបស់ខ្ញុំគាត់ បានចេញលិខិតបំភ្លឺមកច្បាស់ណាស់លើកទី១គាត់បានទទួលពីកូនក្តីរបស់ខ្ញុំ៣០.០០០ដុល្លាលើកទី២បានទទួល ៣០.០០០ដុល្លា សរុប៦០.០០០ដុល្លា កូនក្តីរបស់ខ្ញុំមិនបានសរសេរលំអិតទេគ្រាន់តែសរសេរដក៦០.០០០ដុល្លានៅសល់៤៥.៣០០ដុល្លា។ ហើយនៅថ្ងៃទី០៧-១២-២០១០នេះកូនក្តីខ្ញុំសរសេរខ្វះ៤៥.៣០០ដុល្លា នៅថ្ងៃទី០៩-១២-២០១០កូនក្តីខ្ញុំយកប្រាក់ទៅឲ្យលោក [redacted] ស៊ីហ្វុង ចំនួន១២.៣០០ដុល្លា ហើយលោកជា ហ៊ីមយកទៅឲ្យ៣៣.០០០ អីចឹងសរុបទៅវាគ្រប់ចំនួន៤៥.៣០០ដុល្លា ដូចដែលកូនក្តីខ្ញុំសរសេរនៅក្នុងកំណត់ហេតុនេះ។បណ្តឹងតបរបស់គាត់បានដាក់មែន តែនៅពេលនីតិវិធីត្រៀមគាត់បានទទួលស្គាល់រឿងៗខ្លួនៗសំណូមពរ ភាគីលោក [redacted] ហ៊ីម ថាចេញលុយ១៦.៥០០ ដុល្លា ប៉ុន្តែគាត់ គ្មានភស្តុតាង ដែលថាកូនក្តីខ្ញុំបានទទួលហ្នឹងទេ កូនក្តីរបស់ខ្ញុំអះអាងច្បាស់លាស់គឺគាត់មិនបានទទួលលុយ១៦.៥០០ដុល្លាហ្នឹងទេ។សាក្សីមានលោក [redacted] ស៊ីហ្វុង គាត់ថាគាត់ទទួលលុយ៣៣.០០០ដុល្លា លុយនៅសល់ពីនេះកូនក្តីខ្ញុំចេញទាំងអស់។ដោយមានលិខិតបំភ្លឺរបស់លោក [redacted] ស៊ីហ្វុង មាននៅក្នុងសំណុំរឿង។ តុលាការសាលាដំបូងសម្រេចត្រឹមត្រូវហើយ ខ្ញុំសុំតម្កល់សាលក្រមលេខ៥៥-ច-ចុះថ្ងៃទី១២-១០-២០១១ទុកជាបានការ។

ដើមចោទឈ្មោះ [redacted] ចាន់ថា ឆ្លើយថា:រថយន្តHiprid ពណ៌ខ្មៅ ថ្លៃ៣៦.៥០០ដុល្លាអាមេរិកគឺលុយរបស់ខ្ញុំទាំងអស់ ដែលរថយន្តនេះយកទៅដូរយករថយន្តម៉ាក៣៣០ ក៏លុយរបស់ខ្ញុំដែរ ហើយលោក [redacted] ហ៊ីម បានទៅយកលុយពីខ្ញុំ៣៣.០០០ដុល្លាអាមេរិកនោះជា លុយរបស់ខ្ញុំ ហើយគាត់យកទៅសងលោកឡៅ ស៊ីហ្វុង ។ដល់លក់LESIS 330 បានគាត់ដកយកលុយចំនួន៣៣.០០០ដុល្លាអាមេរិក គាត់មកដកពីខ្ញុំចំនួន៣៣.០០០ដុល្លាអាមេរិក លុយលក់រថយន្ត៣៣០ លក់បានថ្លៃ៣៥០០០ដុល្លាអាមេរិក តែចំណេញចែកគ្នាហើយ នៅសល់ដើមដកពីខ្ញុំចំនួន ៣៣.០០០ដុល្លាអាមេរិក យកទៅឲ្យថៅកែឡាន។សៀវភៅនេះកត់មុន តែជាក់ស្តែងមិនអីចឹងទេ។

**ការអះអាងរបស់ភាគីចុងចម្លើយ ៖**

លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយធ្វើសេចក្តីថ្លែងហេតុថា: លោកចាន់ថា បានប្តឹងកូនក្តីខ្ញុំទាមទារប្រាក់ចំនួន២៤.៨៣៥ដុល្លាអាមេរិក និងជម្ងឺចិត្តមួយម៉ឺនដុល្លាអាមេរិក ក្នុងនោះតុលាការសាលាដំបូងបានសម្រេចឲ្យកូនក្តីខ្ញុំសងទៅដើមចោទចំនួន២២.០៣៥ដុល្លាអាមេរិកនិងជម្ងឺចិត្ត២.០០០ដុល្លាអេមេរិក។កូនក្តីរបស់ខ្ញុំមិនសុខចិត្តបានប្តឹងឧទ្ធរណ៍ពីសាលក្រមរបស់សាលាដំបូង។នៅតុលាការសាលាដំបូងកូនក្តីរបស់ខ្ញុំបានធ្វើបណ្តឹងតបហើយនៅក្នុងបណ្តឹងតបនោះគាត់បានទាមទារឈ្មោះ [redacted] ចាន់ថា សងមកគាត់ចំនួន១ម៉ឺនប្រាំបីពាន់ដុល្លាអាមេរិក និងទាមទារថ្លៃឡានHighlander ពណ៌ខ្មៅ ០១



Scanned with CamScanner

គ្រឿង។ទាក់ទងនឹងការទិញឡានថគ្រឿងដែលមានលិខិតស្នាមសរសេរផ្ទាល់ដៃថាអ្នកណាចេញអី អ្នកណាចេញអី មានភស្តុតាងមួយសន្លឹកនេះ។ឡានថគ្រឿងដែលដើមចោទបានលើកឡើងហើយកូនក្តីរបស់ខ្ញុំបន្ថែមមួយគ្រឿងទៀតHighlander ពណ៌ខ្មៅ។៤គ្រឿងនោះមានឡាន០១០ ពណ៌ស្លែ តម្លៃចំនួន៣៥.០០០ដុល្លាអាមេរិកCAMRY XLE ០២ ថ្លៃ១៦.៥០០ដុល្លាអាមេរិកCAMRY XLE ពណ៌ស្ក ថ្លៃ១៧.៣០០ដុល្លាអាមេរិក និងឡាន CAMRY ០១០ ថ្លៃ៣៦.៥០០ដុល្លាអាមេរិក ដែលទូរលេខទាំងអស់នេះសរុប១០៥.៣០០ដុល្លាអាមេរិក។ទាក់ទងឯកសារឡានCAMRY XLE ០២ថ្លៃ១៦.៥០០ដុល្លាអាមេរិក ដាក់ថាកូនក្តីខ្ញុំជាអ្នកចេញ។ឡានHiprid ០១០ ឡាននេះបានយកទៅដូរយកឡានLesis 330 ពណ៌ស្ក ថ្លៃ៣៣.០០០ដុល្លាអាមេរិក ។តម្លៃនេះដែលកូនក្តីខ្ញុំចេញលុយឲ្យម្ចាស់ឡានឈ្មោះLAV SIHVONG មានការទទួលដោយសែក ហើយឈ្មោះ LAV SIHVONG ក៏បានទទួលដែល។ ដូច្នេះឃើញថា ទឹកលុយសរុបរបស់កូនក្តីខ្ញុំ៣៣.០០០ដុល្លាអាមេរិកនិង១៦.៥០០ដុល្លាអាមេរិក ។នៅក្នុងឡាន៥គ្រឿងឡានពីរគ្រឿងបានលក់ចែកគ្នាហើយ ។ចំណុចវិវាទឡាន៣គ្រឿងឡាន CAMRY XLE ពណ៌ទឹកប្រាក់០២ ១៦.៥០០ដុល្លាអាមេរិក ដាក់ថាហ៊ីមចេញសព្វថ្ងៃលោកអ៊ិន ចាន់ថា បានលក់ហើយបានថ្លៃ១៨.០០០ដុល្លាអាមេរិកចំពោះឡានCAMRY XLE ពណ៌ស្ក០៣ ថ្លៃ ១៧.៣០០ដុល្លាអាមេរិក កូនក្តីខ្ញុំបានលក់ហើយលុយនៅគាត់ ចំពោះឡានHighlander ថ្លៃ១៩.៣០០ ដុល្លាអាមេរិក ឡាននេះដាក់ឈ្មោះកូនកូនក្តីរបស់ខ្ញុំឈ្មោះ [redacted] អេងនៅក្នុងលុយ១៩.៣០០ ដុល្លាអាមេរិក មានចំណែកលុយរបស់កូនក្តីខ្ញុំ១០.៦០០ដុល្លាអាមេរិក។ ក្រៅពីនោះជាចំណែករបស់លោកអ៊ិន ចាន់ថាអីចឹងឃើញចំណុចខ្វែងគ្នាឃើញឡាន៣ មួយCAMRY XLE ១៦.៥០០ដុល្លាអាមេរិកលក់បាន១៨.០០០ដុល្លាអាមេរិក សព្វថ្ងៃនៅភាគីអ៊ិន ចាន់ថា CAMRY XLE ពណ៌ ស្ក០៣ ថ្លៃ១៧.៣០០ដុល្លាអាមេរិក លក់ហើយលុយនៅកូនក្តីខ្ញុំ។ឡានHighlander ពណ៌ខ្មៅ ថ្លៃ ១៩.៣០០ដុល្លានៅភាគីអ៊ិន ចាន់ថា គ្រប់គ្រង។ដូច្នេះដើម្បីគណនាលើចំណុចខ្វែងគ្នានេះសរុបកូនក្តីខ្ញុំមានលុយ១៦.៥០០ដុល្លា មានលុយ១០.៦០០ដុល្លានៅក្នុងHighlander ហើយកូនក្តីខ្ញុំចង់ទាមទារ១.៥០០ដុល្លា នៅក្នុងចំណែកឡាន១៨.០០០ដុល្លា ស្មើ២៨.៦០០ដុល្លានេះជាលុយដែលកូនក្តីរបស់ខ្ញុំត្រូវបាន។ប៉ុន្តែដោយសារកូនក្តីខ្ញុំមានឡានមួយ ដែលគាត់លក់ហើយថ្លៃ១៧.៣០០ដុល្លា ដូច្នេះការដកផលសងទៅភាគី [redacted] ចាន់ថា នៅខ្វះកូនក្តីខ្ញុំចំនួន១១.៣០០ដុល្លា ព្រោះភាគី [redacted] ចាន់ថា នៅឡាន២គ្រឿង មួយថ្លៃ១៨.០០០ដុល្លានិងមួយទៀត១៩.៣០០ដុល្លា សរុប៣៧.៣០០ដុល្លា។ កូនក្តីរបស់ខ្ញុំបានដាក់ពាក្យបណ្តឹងតបជាលាយលក្ខ័អក្សរ។ កូនក្តីខ្ញុំនៅតែទាមទាររថយន្តHighlander នៅតែទាមទារមាននៅក្នុងសេចក្តីថ្លែងការហើយ ទី១-សុំបដិសេធសាលក្រមលេខ៥៥-ច-ចុះថ្ងៃទី១២-១០-២០១១ ចោលជាអាសារបង់និងសុំច្រានចោលពាក្យបណ្តឹងរបស់ដើមចោទ និងសុំឲ្យដើមចោទសង ប្រាក់ចំនួន១១.៣០០ដុល្លាអាមេរិក។

ចុងចម្លើយឈ្មោះ[redacted] ហ៊ីម ឆ្លើយថាៈឡាន៤គ្រឿងគឺបានបែងចែក អ្នកណាចេញប៉ុន្មាន? អ្នកណាចេញប៉ុន្មាន ទី១CAMRY XLE ០១០ថ្លៃ៣៥.០០០ដុល្លា[redacted] ចាន់ថា អ្នកចេញ។ខ្ញុំចេញលុយឲ្យម្ចាស់ឡាន៣៣.០០០ដុល្លា ដូរយកLesis 330 ។លុយ៣៣.០០០ដុល្លាដូរជាថ្នូរចេញសែកឲ្យម្ចាស់លក់ឡាន ហើយម្ចាស់ឡានក៏បានទទួលស្គាល់ថា បានទទួលលុយពីខ្ញុំ៣៣.០០០ដុល្លានោះដែរ។ឡានHilander ថ្លៃ១៩.៣០០ដុល្លាទិញចូល គ្នាជាមួយ[redacted] ចាន់ថា លុយខ្ញុំចេញ ១០.៦០០ដុល្លាហើយ[redacted] ចាន់ថា ចេញ៨.៧០០ដុល្លា។ លោក[redacted] ចាន់ថា ចង់និយាយរថយន្តHYPRID 2010 ថ្លៃ៣៦.៥០០ដុល្លាអាមេរិក ហើយខ្ញុំឯកភាពជាមួយគាត់យកទៅដូររថយន្ត៣៣០ តម្លៃ៣៣.០០០ដុល្លាអាមេរិក គេថែមមកយើងចែកគ្នាហើយ ដល់ថ្ងៃទី០៩-១២-២០១០ខ្ញុំបានចេញសែក ហើយប្រាប់ថា ទៅគិតគូរជាមួយថៅកែឡានទៅ ហើយខ្ញុំចេញសែក៣៣.០០០ដុល្លាអាមេរិក ទូទាត់ជាមួយលោក[redacted] ស៊ីហ៊ុង ។ខ្ញុំចេញសែកឲ្យលោក[redacted] ស៊ីហ៊ុង ចំនួន៣៣.០០០ដុល្លាអាមេរិក ហើយលក់ឡានបានខ្ញុំដកដើមខ្ញុំមកវិញ។ ខ្ញុំប្ដឹងឧទ្ធរណ៍មិនសុខចិត្តចំណុចទាំងមូល ។ឡាន XLE 02 នេះនៅក្នុងចង្កោមឡាន៤គ្រឿង ខ្ញុំទូទាត់ឲ្យលោកអ៊ិន ចាន់ថាថ្ងៃទី០៧-១២- បានលោកអ៊ិន ចាន់ថា ដាក់ឈ្មោះហ៊ីម ជាអ្នកចេញ ១៦.៥០០ដុល្លា ។ រថយន្ត៤គ្រឿងតម្លៃ១០៥.៣០០ដុល្លាអាមេរិក ដកចំនួន១៦.៥០០ដុល្លា នៅសល់៨៨.៨០០ដុល្លា ហើយបានយកទៅប្រគល់ឲ្យរៀង១ខ្លួនគាត់ក៏បានចុះបញ្ជីគាត់ខ្ញុំក៏បានចុះបញ្ជីខ្ញុំដែរ។ នៅតុលាការសាលាដំបូងមិនបាននិយាយពីបណ្ដឹងតបរបស់ខ្ញុំទេ។

**សំអាងហេតុ ៖**

១.បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៨-១១-២០១១របស់លោកប៊ុន កែវលឹម មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ[redacted] ហ៊ីម ប្ដឹងឧទ្ធរណ៍ និងសាលក្រមរដ្ឋប្បវេណីលេខ៥៥ "ច"ចុះថ្ងៃទី១២-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំនុចទី១(ក,ខ)និងត្រង់ចំនុចទី២ទាំងមូលធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានយោងតាមមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២.តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ឃើញថាៈ ទាំងដើមចោទឈ្មោះ[redacted] ចាន់ថា និងទាំងចុងចម្លើយឈ្មោះ[redacted] ហ៊ីម សុទ្ធតែបានបដិសេធចោលនូវអំណះអំណាងរបស់ភាគីរៀង១ខ្លួន ដូចជាដើមចោទបានអះអាងថាចុងចម្លើយនៅជំពាក់ខ្លួនប្រាក់ថ្លៃទូទាត់បែងចែកភាគហ៊ុនលក់រថយន្តដែលនៅសល់ផ្ដាច់ពីគ្នាចំនួន៧.៥៣៥$ ។ ឯចុងចម្លើយអះអាងថាៈដើមចោទជំពាក់ខ្លួនចំនួន១០.៦០០$ ដែលជាប្រាក់របស់ខ្លួនក្នុងការទិញរថយន្តម៉ាក Toyota Highlander ផលិតឆ្នាំ២០០២ ពណ៌ខ្មៅជាមួយដើមចោទដែលសព្វថ្ងៃដើមចោទជាអ្នកគ្រប់គ្រង ។ ចំណុចនេះសាលាឧទ្ធរណ៍យល់ឃើញថាៈ ការ

អះអាងរបស់គូភាគីពុំមានភស្តុតាង ឬ សាក្សីដែលជាមូលដ្ឋានដើម្បីពិចារណាឡើយដែល គប្បីសាលាឧទ្ធរណ៍លុបចោល និងច្រានចោលការទាមទារ ។

៣.ចំពោះរថយន្តម៉ាកCAMARY XLE ពណ៌ទឹកប្រាក់តម្លៃ១៦.៥០០$ គឺជាចំណុចវិវាទក្នុងរឿងនេះ តើចុងចម្លើយបានចេញប្រាក់ថ្លៃទិញរថយន្តនេះចំនួន១៦.៥០០$ឲ្យទៅដើមចោទឬទេ?។បើពិនិត្យលើកំណត់ត្រាផ្ទាល់ខ្លួនរបស់ដើមចោទ បានសរសេរចុះថ្ងៃទី២៣-១១-២០១០សំគាល់ថា: ទិញ ហ៊ុមចេញគឺរថយន្តម៉ាក 330 ពណ៌ស្ករឆ្នាំ2004 ចំនួន៣៣.000$ ដែលស្របនឹងចម្លើយទទួលស្គាល់អ្នកលក់រថយន្តឈ្មោះ LAV SIHVONG និងដើមចោទ។ប៉ុន្តែចំពោះរថយន្តម៉ាកCAMARY XLE ពណ៌ទឹកប្រាក់ 02 តំលៃ១៦.៥០០$ ក៏ដើមចោទបានសរសេរក្នុងកំណត់ត្រាផ្ទាល់ខ្លួនដែរ ចុះថ្ងៃទី០៧-១២-២០១០ថា:ហ៊ុមចេញ។ ចំណុចនេះសាលាឧទ្ធរណ៍យល់ឃើញថា:ពុំមានហេតុផលណាមួយថាចុងចម្លើយមិនបានចេញប្រាក់ថ្លៃរថយន្តនេះដូចការអះអាងរបស់ដើមចោទទេ ។

៤.រថយន្តម៉ាកCAMARYXLE ពណ៌ទឹកប្រាក់02 ត្រូវបានចុងចម្លើយចេញប្រាក់ទិញ ហើយយកទៅជួសជុលអស់ប្រាក់១.៥០០$ ហើយដើមចោទយកទៅលក់បានតម្លៃ១៨.000$។ ឯរថយន្តម៉ាកCAMARY XLE ពណ៌ស្ករ 03 តម្លៃ១៧.៣០០$ ដែលជាប្រាក់របស់ដើមចោទចេញហើយត្រូវបានចុងចម្លើយយកទៅលក់មានតម្លៃស្មើដើមគឺ១៧.៣០០$ ដូច្នេះដើមចោទនៅជំពាក់ចុងចម្លើយចំនួន៧០០$ ។

៥.ជំងឺចិត្តចំនួន២.០០០$ ដែលសាលក្រមរបស់សាលាដំបូងបានសម្រេចឲ្យចុងចម្លើយសងទៅឲ្យដើមចោទនោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថាពុំមែនជាកំហុសរបស់ចុងចម្លើយទេ គប្បីសាលាឧទ្ធរណ៍លុបចោល ។

៦.ចំណុចទី១(ក,ខ)និងចំណុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ៥៥-ច" ចុះថ្ងៃទី១២-១០-២០១១របស់សាលាដំបូងរាជធានីភ្នំពេញដែលបានសម្រេចមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ គប្បីសាលាឧទ្ធរណ៍លុបចោល និងសម្រេចជាថ្មីតាមសំអាងហេតុដែលបានលើកឡើងខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១.ទទួលបណ្ដឹងចុះថ្ងៃទី០៨-១១-២០១១ របស់លោក[redacted] ទុកជាត្រឹមត្រូវតាមច្បាប់ ។

២.លុបចោលចំណុចទី១(ក,ខ)និងចំនុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ៥៥ "ច" ចុះថ្ងៃទី១២-១០-២០១១របស់សាលាដំបូងរាជធានីភ្នំពេញចោលជាអាសារបង់និងសម្រេចជាថ្មីដូចតទៅ:

-បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] ចាន់ថា សងប្រាក់ចំនួន៧០០$ (ប្រាំពីររយ)ដុល្លា 40/1
អាមេរិក ទៅចុងចម្លើយឈ្មោះ [redacted] ហ៊ុម ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ចាន់ថា ។

សាលដីកានេះ ប្រកាសជាសាធារណៈថ្ងៃទី១៦-១១-២០១២ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|

ហត្ថលេខា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ភ្នំពេញ, ថ្ងៃទី [illegible] ខែ ០៥ ឆ្នាំ ២០១២
ក្រឡាបញ្ជី

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

[redacted]



១០៤
104